សេចក្តីបោះពុម្ពព័ត៌មាន

របាយការណ៍របស់អង្គការពលកម្មអន្តរជាតិរកឃើញពីកំណើនសេដ្ឋកិច្ចយឺតយ៉ាត និង ទីផ្សារការងារទន់ខ្សោយ នៅអាស៊ីអាគ្នេយ៍

ប៊ីសាន (ព័ត៌មានរបស់អង្គការពលកម្មអន្តរជាតិ) -- អាស៊ីអាគ្នេយ៍ និង តំបន់ប៉ាស៊ីហ្វិក[1] បានប្រឈមជាមួយនឹងការធ្លាក់ចុះនូវកំណើនសេដ្ឋកិច្ច ការបង្កើតការងារដែលមានលក្ខណៈទន់ខ្សោយ និង ភ័ក្តិតខ្ពស់នៃភាពគ្មានការងារគ្រប់គ្រាន់ដើម្បីធ្វើសមនឹងលទ្ធភាព ចាប់តាំងពីវិបត្តិហិរញ្ញវត្ថុនៅក្នុងឆ្នាំ ១៩៩៧ មក នេះបើតាមរបាយការណ៍ថ្មីមួយ ដែលចេញដោយអង្គការពលកម្មអន្តរជាតិ ។

សេដ្ឋកិច្ចនៅតំបន់ប៉ាស៊ីហ្វិក មានការអនុវត្តន៍អន់ជាងគេបំផុត បើប្រៀបធៀបនឹងតំបន់ដទៃទៀតនៅអាស៊ី ។

របាយការណ៍និយាយថា បើទោះបីជាកំណើនការងារងើបឡើងបន្តិចបន្តួចនៅក្នុងឆ្នាំ ២០០៥ ដែលបង្កើនសេចក្តីសង្ឃឹមថាកំណើនសេដ្ឋកិច្ច រួមជាមួយនឹងកំណើនការងារអាចបន្តកាត់បន្ថយភាពក្រីក្រ នៅក្នុងអនុតំបន់នេះក៏ដោយ ក៏ការអនុវត្តរបស់សេដ្ឋកិច្ច និង ទីផ្សារការងារ ពុំមានសភាពដូចគ្នានឹងជោគជ័យមុនឆ្នាំ ១៩៩៧ ឡើយ ។

របាយការណ៍ ដែលមានចំណងជើងថា "និន្នាការការងារ និង សង្គមនៅអាស៊ី និង ប៉ាស៊ីហ្វិក ឆ្នាំ២០០៦: វឌ្ឍនភាពឆ្ពោះទៅរកការងារផ្ទៃផ្ទ្ទរ" ត្រូវបានរៀបរៀងឡើងដោយអង្គការពលកម្មអន្តរជាតិ (ILO) ដែលជាភ្នាក់ងាររបស់អង្គការសហប្រជាជាតិខាងបញ្ហាការងារ និង បញ្ហាដែលកើតឡើងនៅកន្លែងធ្វើការ ។

យោងទៅតាមរបាយការណ៍នេះ ប្រទេសកម្ពុជា និង ប្រទេសវៀតណាមគឺជាប្រទេសដែលមានការអនុវត្តន៍ផ្នែកសេដ្ឋកិច្ចល្អជាងគេនៅក្នុងអនុតំបន់ ចាប់តាំងពីឆ្នាំ ២000 មក ដោយអត្រាកំណើន GDP ប្រចាំឆ្នាំជាមធ្យមសំរាប់ប្រទេសកម្ពុជា ៧,៣% និង វៀតណាម ៦,៥% ។ ម៉ាឡេស៊ីក៏ទទួលលទ្ធផលសេដ្ឋកិច្ចល្អប្រសើរផងដែរ ដោយមានអត្រាកំណើន GDP ប្រចាំឆ្នាំជាង ៥% នៅរវាងឆ្នាំ ២០០៣ និង ២០០៥ ។ ផ្ទុយទៅវិញ កំណើនសេដ្ឋកិច្ចបានធ្លាក់ចុះ នៅក្នុងប្រទេសថៃ និង សិង្ហបុរី នៅកំឡុងឆ្នាំ ២០០៥ ។

---

[1] ប្រ៊ុយណេ កម្ពុជា ហ្ជីជី ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី ភូមា ប៉ាពូញូហ្គីនី ហ្វីលីពីន សិង្ហបុរី កោះសូឡូម៉ុន ថៃ ទីម័រឡេស វៀតណាម

ការិយាល័យតំបន់សំរាប់អាស៊ី និង ប៉ាស៊ីហ្វិក អាគារអង្គការសហប្រជាជាតិ រាជដាំនើនណុក បាងកក ១០២០០ ប្រទេសថៃ
ទូរស័ព្ទ: (66) 2288 2482; ទូរសារ: (66) 2288 1076; អ៊ីមេល bangkok@ilo.org វ៉ិបសាយ www.ilo.org/asia និង www.ilo.org

យ៉ាងណាក៏ដោយ ស្ទើរតែគ្រប់ប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍ មានអត្រាអ្នកអត់ការងារនៅក្នុងឆ្នាំ ២០០៤ ច្រើនជាងក្នុងឆ្នាំ ១៩៩៥ ដែលនេះសបញ្ជាក់ថាផលប៉ះពាល់នៃវិបត្តិក្នុងឆ្នាំ ១៩៩៧ នៅតែកំពុងមាននៅឡើយ។ បើទោះបីជា GDP នៅក្នុងប្រទេសឥណ្ឌូនេស៊ីមានការកើនឡើង (ជាពិសេស នៅក្នុងឧស្សាហកម្ម) ក៏ដោយ ក៏កំណើននេះនៅពុំទាន់សមល្មមនឹងបង្កើតការងារអោយបានគ្រប់គ្រាន់ ដើម្បីស្រូបយកនិយោជិតថ្មីៗប្រហែលជា ២ ទៅ ២,៥ លាននាក់ ដែលចូលមកក្នុងទីផ្សារការងារជារៀងរាល់ឆ្នាំឡើយ។ ដូច្នេះហើយ ភាពអត់ការងារធ្វើនៅក្នុងប្រទេសឥណ្ឌូនេស៊ីបានកើនឡើងយ៉ាងឆាប់រហ័សពី ៦,១% នៅក្នុង ឆ្នាំ ២០០០ រហូតដល់ ៩,៩% នៅក្នុងឆ្នាំ ២០០៤។ ចំពោះចំនុចវិជ្ជមានវិញ របាយការណ៍នេះរកឃើញថា ផលិតភាពការងារនៅឥណ្ឌូនេស៊ី បានកើនឡើងជាង ១៤% នៅរវាងឆ្នាំ ២០០០ និង ២០០៤។

អត្រាអ្នកអត់ការងារធ្វើនៅក្នុងប្រទេសម៉ាឡេស៊ី កើនឡើងពី ៣ ទៅ ៣,៥ ភាគរយ នៅចន្លោះឆ្នាំ ២០០០ និង ២០០៤។ ភាពអត់ការងារធ្វើនៅក្នុងប្រទេសហ្វីលីពីនបានកើនឡើងរហូតដល់ ១០,៩% នៅក្នុងឆ្នាំ ២០០៤។

អត្រាអ្នកអត់ការងារធ្វើនៅក្នុងប្រទេសថៃ បានធ្លាក់ចុះ ក្នុងរវាងឆ្នាំ ២០០០ និង ២០០៤ ដែលនេះឆ្លុះបញ្ចាំងពីកំណើនយ៉ាងរឹងមាំខាងទិន្នផល និង ផលិតភាពការងារ សំរេចបាននៅក្នុងរយៈពេលនេះ។

របាយការណ៍នេះក៏ព្រមានផងដែរពីអត្រាភាពគ្មានការងារគ្រប់គ្រាន់ដើម្បីធ្វើសមនឹងលទ្ធភាព ដ៏គួរអោយព្រួយបារម្ភនៅក្នុងអនុតំបន់នេះ ជាពិសេសនៅក្នុងប្រទេសឥណ្ឌូនេស៊ី និង ហ្វីលីពីន។ នៅឥណ្ឌូនេស៊ី មានកម្មករនិយោជិតសរុបចំនួន ៣១,៤ លាននាក់ នៅក្នុងឆ្នាំ ២០០២ (ឬ ស្មើនឹង ៣៤,៣% នៃកំលាំងការងារទាំងមូល) មានការងារធ្វើមិនគ្រប់គ្រាន់ (ធ្វើការតិចជាង ៣៥ ម៉ោងក្នុងមួយ សប្តាហ៍) បើប្រៀបធៀបនឹងចំនួន ៣៤,១ លាននាក់ នៅក្នុងឆ្នាំ ១៩៩៦ នេះបើតាមទិន្នន័យដែលបានមកពីការសិក្សាលើកំលាំងការងារ។

លោក Gyorgy Sziraczki ប្រធានផ្នែកវិភាគសេដ្ឋកិច្ច និង សង្គម នៃការិយាល័យប្រចាំតំបន់អាស៊ី និង ប៉ាស៊ីហ្វិក នៃអង្គការពលកម្មអន្តរជាតិ ដែលជាអ្នករៀបរៀងរបាយការណ៍នេះ ពន្យល់ថា "មូលហេតុមួយ ដែលធ្វើអោយការប្រតិបត្តិរបស់ទីផ្សារការងារមានលក្ខណៈអន់ខ្សោយ នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ គឺដោយសារតែសេដ្ឋកិច្ចរបស់ប្រទេសមួយចំនួន នៅមិនទាន់បានធូរស្រាលអោយបានពេញលេញ ពីវិបត្តិហិរញ្ញវត្ថុនៅអាស៊ីនៅឡើយ។ នេះគឺការពិតជាពិសេស ចំពោះប្រទេសឥណ្ឌូនេស៊ីដែលជាសេដ្ឋកិច្ចធំជាងគេនៅក្នុងអនុតំបន់"។

លោកបានមានប្រសាសន៍ថា "នៅរវាងពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១៥ មានមនុស្សចំនួន ៥,៦ លាននាក់ នឹងឈានជើងចូលទៅក្នុងទីផ្សារការងាររបស់អនុតំបន់ ជារៀងរាល់ឆ្នាំ។ បើទោះបីជាជោគជ័យក្នុងការកាត់បន្ថយភាពក្រីក្រការងារកើតមានឡើងជាបន្តបន្ទាប់ក៏ដោយ ប្រទេសនៅអាស៊ីអាគ្នេយ៍ចាំបាច់ត្រូវបង្កើតឱកាសការងារថ្មីៗ ដើម្បីបញ្ជៀសមិនអោយមានភាពនៅនឹងមួយកន្លែង នៃអត្រាអ្នកគ្មានការងារធ្វើ និង អត្រាភាពគ្មានការងារគ្រប់គ្រាន់ដើម្បីធ្វើសមនឹងលទ្ធភាពនាពេលអនាគត"។

អនុតំបន់ប៉ាស៊ីហ្វិក បានជួបប្រទះនឹងការអនុវត្តន៍ផ្នែកសេដ្ឋកិច្ចអន់បំផុត នៅអាស៊ី ។ នៅក្នុងឆ្នាំ ២០០៥ GDP កើនឡើង ២,៣% នៅតំបន់ប៉ាស៊ីហ្វិក បើប្រៀបធៀបជាមួយនឹងអត្រាកំណើនរួម ៧,៣% នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ី ។ ការអនុវត្តន៍ផ្នែកសេដ្ឋកិច្ចដែលមានលក្ខណៈអន់ខ្សោយ រួមផ្សំជាមួយនឹងចំនួនប្រជាពលរដ្ឋ និង កំណើនកំលាំងការងារយ៉ាងខ្ពស់ ធ្វើអោយមានការធ្លាក់ចុះជីវភាពរស់នៅ និង ធ្វើអោយស្ថានភាពការងារធ្លាក់ក្នុងសភាពដុនដាប នៅក្នុងបណ្តាប្រទេសជាច្រើន នៅតំបន់ប៉ាស៊ីហ្វិក ។

របាយការណ៍ បានលើកយកប្រទេសប៉ាពួញូហ្គីនី មកធ្វើជាឧទាហរណ៍ ដើម្បីបង្ហាញពីបញ្ហាប្រឈមដ៏ធំនេះ ។ សេដ្ឋកិច្ចរបស់ប្រទេសនេះ កើនឡើង ២,៥% នៅក្នុងឆ្នាំ ២០០៤ ដែលជាឆ្នាំទី ៣ នៃកំណើនវិជ្ជមានតែប៉ុណ្ណោះ ចាប់តាំងពីឆ្នាំ ១៩៩៦ មក ។ នៅក្នុងឆ្នាំ ២០០៥ សេដ្ឋកិច្ចកើនឡើងប្រមាន ២,៥% ហើយ មានកំណើនការងារ ១,៥% បើប្រៀបធៀបទៅនឹងអត្រាក្នុងឆ្នាំកន្លងទៅ ។ ទោះបីនេះជាសញ្ញាវិជ្ជមានមួយក៏ដោយ កំណើនសេដ្ឋកិច្ច និង ភាពរីកចំរើនខាងផលិតភាពរបស់ប្រទេសនេះ នៅតែនៅពីក្រោយប្រទេសផ្សេងទៀតនៅអាស៊ី ។

របាយការណ៍នេះ នឹងចេញផ្សាយនៅឯកិច្ចប្រជុំប្រចាំតំបន់អាស៊ីរបស់អង្គការពលកម្មអន្តរជាតិ ដែលនឹងធ្វើឡើងនៅក្រុងប៊ូសាន ប្រទេសកូរ៉េខាងត្បូងពីថ្ងៃទី ២៥ សីហា ដល់ ថ្ងៃទី ១ កញ្ញា ២០០៦ ។ តំណាងមកពីរដ្ឋាភិបាល អង្គភាពនិយោជិត និងអង្គភាពនិយោជក មកពីអាស៊ីខាងត្បូង ក្នុងចំណោមប្រទេសចំនួន ៤0 នឹងចូលរួមក្នុងកិច្ចប្រជុំនេះ ។ កិច្ចប្រជុំនេះនឹងផ្តោតទៅលើផលប៉ះពាល់នៃសកលភាវូនីយកម្ម លើទីផ្សារការងារ និង ភាពអាចរកការងារធ្វើបាន ។ កិច្ចប្រជុំនេះធ្វើឡើងរៀងរាល់ ៤ ឆ្នាំម្តង ។

សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:

Sophy Fisher
មន្ត្រីព័ត៌មានប្រចាំតំបន់របស់អង្គការពលកម្មអន្តរជាតិ
Fisher@ilo.org
ទូរស័ព្ទ: +82 1086598535/+662 288 1664

Krisdaporn Singhaseni
មន្ត្រីព័ត៌មានអង្គការពលកម្មអន្តរជាតិ
Krisdaporn@ilo.org
ទូរស័ព្ទ: + 662 288 1664